ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី លទ្ធផលនៃកិច្ចប្រជុំលើកទី១
# របស់ក្រុមការងារឆ្លើយតបការរាតត្បាតនៃវីរុសកូរ៉ូណាថ្មី (2019-nCoV)

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា ដើម្បីបន្តកិច្ចការសំខាន់ៗសម្រាប់ការឆ្លើយតបការរាតត្បាតនៃវីរុសកូរ៉ូណាថ្មី (2019-nCoV) ឲ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់ និងការរៀនសូត្របទពិសោធន៍នៃការគ្រប់គ្រង ការឆ្លើយតប ការស្រាវជ្រាវ ការពិនិត្យ និងការព្យាបាលអ្នកជំងឺដែលមានវិជ្ជមានវីរុសកូរ៉ូណាថ្មីនេះ កិច្ចប្រជុំក្រុមការងារឆ្លើយតបការរាតត្បាតនៃវីរុសកូរ៉ូណាប្រភេទថ្មី(2019-nCoV) បានប្រព្រឹត្តទៅនារសៀលថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០ នៅទីស្តីការក្រសួងសុខាភិបាល ក្រោមអធិបតីភាព **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានក្រុមការងារ ដែលមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាអនុប្រធានក្រុមការងារ សមាជិក-សមាជិកានិងទីប្រឹក្សាបច្ចេកទេសនៃក្រុមការងារខាងលើ សរុបមានចំនួន ៥៥ នាក់។

គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិនិត្យឡើងវិញនូវបទពិសោធន៍នៃយន្តការគ្រប់គ្រង ពិភាក្សាឆ្មារិះរកនីតិវិធីប្រទាក់ក្រឡា និងការពង្រឹងយន្តការនៃការឆ្លើយតប ការស្រាវជ្រាវ និងការទប់ស្កាត់ការចម្លងវីរុសកូរ៉ូណាថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការដាក់ចេញនូវវិធានការបន្តទៀត បើទោះជាក្រសួងសុខាភិបាល នៅតែមិនទាន់រកឃើញថាមានប្រជាពលរដ្ឋកម្ពុជា ឬជនបរទេសណាម្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានវិជ្ជមានវីរុសកូរ៉ូណាថ្មីនេះនៅឡើយក៏ដោយ ក្រៅតែពីមានមួយករណីវិជ្ជមានវីរុសកូរ៉ូណាថ្មីនេះនៅលើជនជាតិចិននៅខេត្តព្រះសីហនុ ហើយដែលបុរសជនជាតិចិនរូបនេះបានជាសះស្បើយចេញពីមន្ទីរពេទ្យខេត្តព្រះសីហនុនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ កន្លងមកនេះ។ ៖

លទ្ធផលនៃអង្គប្រជុំក្រុមការងារឆ្លើយតបការរាតត្បាតនៃវីរុសកូរ៉ូណាប្រភេទថ្មី (2019-nCoV) មានជាសង្ខេបដូចតទៅ៖

- បន្តពង្រឹងទៅលើប្រព័ន្ធតាមដានជំងឺឆ្លងដែលមានស្រាប់ និងអង្កេតស្រាវជ្រាវអ្នកប៉ះពាល់ និងករណីសង្ស័យ ព្រមទាំងធ្វើបច្ចុប្បន្នភាពទិន្នន័យអេពីដេមីសាស្ត្រ ទាក់ទងនឹងការឆ្លងវីរុសកូរ៉ូណាប្រភេទថ្មី(2019-nCoV) ទាំងក្នុង និងក្រៅប្រទេស។
- ពិនិត្យឡើងវិញនូវគោលការណ៍ណែនាំប្រតិបត្តិ ពិធីសារសម្រាប់ការគ្រប់គ្រងអ្នកជំងឺ និងរៀបចំផែនការបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលជាបន្តទៀត ក្នុងនោះក៏ត្រូវពង្រឹងលើសមត្ថភាពក្នុងការគ្រប់គ្រងឆ្លើយតបទៅនឹងព័ត៌មានក្លែងក្លាយប្រឌិតមិនពិតដែលធ្វើឲ្យមានការយល់ច្រឡំមកលើកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង និងអាចបង្កភាពចលាចលក្នុងសង្គម ដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់ប្រទេសកម្ពុជា ដោយមានកិច្ចសហការជាមួយអង្គការសុខភាពពិភពលោក និងដៃគូសុខាភិបាលផ្សេងៗទៀត។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) [illegible] ៨៨៤ ៩០៩

- ពិនិត្យលើផែនការនិងការត្រៀមជាស្រេចសម្រាប់ការផ្គត់ផ្គង់ឱសថ សម្ភារបរិក្ខារពេទ្យ និងសម្ភារការពារខ្លួន PPE ចាំបាច់ឲ្យបានសមស្របទៅនឹងតម្រូវការទៅតាមស្ថានភាពជាក់ស្តែង
- ពិនិត្យខ្លឹមសារឡើងវិញ និងបន្តផលិតឯកសារអប់រំសុខភាពពាក់ព័ន្ធនានា ផ្សព្វផ្សាយ ចេញសេចក្តីប្រកាសព័ត៌មានជូនដល់សាធារណជន
- បន្តបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាល លើបច្ចេកទេសគ្រប់គ្រងនិងការពារជំងឺឆ្លង និងផ្តល់ការបណ្តុះបណ្តាលដល់អ្នកសារព័ត៌មាន ដើម្បីឲ្យបានយល់ដឹងពីជំងឺរលាកសួតដោយវីរុសកូរ៉ូណាបន្ថែមទៀត ដែលអាចឲ្យមានការចេញផ្សាយព័ត៌មានបានត្រឹមត្រូវ និងកាត់បន្ថយបានជាអតិបរិមានូវព័ត៌មានខុសឆ្គង ឬព័ត៌មានមិនពិត ដែលចេះតែសរសេរតាមតែពាក្យចចាមអារ៉ាម
- បន្តអប់រំសុខភាពដល់ប្រជាជនទូទៅ សហគមន៍ សិស្សានុសិស្ស អាណាព្យាបាល និងជនងាយរងគ្រោះ
- បន្តចុះត្រួតពិនិត្យ និងពង្រឹងការងារចត្តាឡីស័កនៅតាមច្រកចេញ-ចូល
- បន្តត្រួតពិនិត្យរៀបចំទីតាំងដាក់អ្នកជំងឺឲ្យនៅដោយឡែក ចំពោះករណីសង្ស័យ និងអ្នកប៉ះពាល់ជិតស្និទ្ធជាមួយអ្នកជំងឺ
- បន្តត្រួតពិនិត្យការរៀបចំបន្ទប់ដាក់អ្នកជំងឺឲ្យនៅដោយឡែកសម្រាប់អ្នកជំងឺដែលមានវីរុសកូរ៉ូណាប្រភេទថ្មី (2019-nCoV) នៅតាមមន្ទីរពេទ្យថ្នាក់កណ្តាល និងរាជធានី ខេត្ត
- មន្ទីរសុខាភិបាលរាជធានី ខេត្ត ត្រូវធ្វើការវាយតម្លៃអំពីតម្រូវការបុគ្គលិកសុខាភិបាល និងចាត់ចែងបុគ្គលិកទៅតាមតម្រូវការជាក់ស្តែងឲ្យបានទាន់ពេលវេលា ក្នុងការឆ្លើយតបនិងផ្តល់អន្តរាគមន៍ឲ្យមានប្រសិទ្ធភាព ដោយសហការជាមួយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងនាយកដ្ឋានមន្ទីរពេទ្យនៃក្រសួងសុខាភិបាល ព្រមទាំងមន្ទីរពេទ្យជាតិ ក្នុងករណីចាំបាច់
- រាយការណ៍ពីការរាតត្បាត និងវឌ្ឍនភាពនៃការឆ្លើយតបជូនឯកឧត្តមប្រធានក្រុមការងារឆ្លើយតបការរាតត្បាតនៃវីរុសកូរ៉ូណាថ្មីនៃក្រសួងសុខាភិបាល ឲ្យបានភ្លាមៗ និងទៀងទាត់
- ធ្វើការសិក្សាស្រាវជ្រាវ ចងក្រងឯកសារ ពាក់ព័ន្ធទៅនឹងការរកឃើញករណីវិជ្ជមានវីរុសកូរ៉ូណាថ្មីនៅកម្ពុជា និងបទពិសោធន៍នៃការរុករក គ្រប់គ្រងករណី និតិវិធីនៃការព្យាបាលអ្នកជំងឺ ។ល។
- ស្នើអង្គការសុខភាពពិភពលោក បន្តផ្តល់ការគាំទ្រទាំងបច្ចេកទេស ថវិកា និងជួយសម្របសម្រួលជាមួយដៃគូសុខាភិបាល ក្នុងការស្វែងរកការឧបត្ថម្ភបច្ចេកទេសនិងថវិកា សម្រាប់សកម្មភាពការឆ្លើយតបសមស្របបានទាន់ពេលវេលា។

ថ្ងៃអង្គារ ៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០